# សេចក្តីជូនដំណឹង

## ស្តីពីវិធានការបង្ការ និងទប់ស្កាត់ការរីករាតត្បាតនៃវីរុសកូវីដ១៩

ថ្ងៃទី១៨ ខែ មីនា ឆ្នាំ២០២០

**ជូនចំពោះ៖** **បុគ្គលិក អង្គការ គណៈកម្មាធិការ សហប្រតិបត្តិការដើម្បីកម្ពុជា** (គ.ស.ក)
**អង្គការសមាជិក និង ដៃគូទាំងអស់**

យោងតាមសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា អង្គការសុខភាពពិភពលោក (WHO) និងការចង្អុលបង្ហាញ ពីគណៈកម្មាធិការប្រតិបត្តិ របស់អង្គការ គ.ស.ក និង វិធានការរបស់អង្គការ គ.ស.ក ចំពោះជំងឺឆ្លងរាតត្បាត **វីរុសកូវីត១៩** យើងខ្ញុំបានបង្កើតគោលការណ៍ណែនាំ សម្រាប់ការ ការពារផ្ទាល់ខ្លួន និងសម្រាប់ស្ថាប័ន ក៏ដូចជាចូលរួមការពារនៃការរីករាលដាលនៃ **វីរុសកូវីត១៩** នៅក្នុងទីសាធារណៈ។ វិធីការពារទាំងនោះមានដូចជា៖

### គំរិតនៃការការពារខ្លួនឯងផ្ទាល់:

១) លាងសំអាតដៃរបស់អ្នកជាមួយនឹង សាប៊ូ ទឹកលាងដៃអនាម័យ ឬក៏ជាមួយអាល់កុល

២) ពាក់ម៉ាស់ឲ្យបានត្រឹមត្រូវនៅទីសាធារណៈ ការប្រើប្រាស់ក្រដាសអនាម័យ ដោយមានការបោះចោលអោយបានសមស្រប

៣) តាមដានយ៉ាងយកចិត្តទុកដាក់អំពី បច្ចុប្បន្នភាពនៃជំងឺរាតត្បាត **វីរុសកូវីត១៩** ជាពិសេសប្រភពព័ត៌មាន ដែលច្បាស់លាស់ដូចជា ក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោក

៤) ជៀសវាងការប្រមូល ផ្តុំគ្នាជាក្រុមធំៗ ដោយធ្វើទៅតាម ការណែនាំពីក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា និងអង្គការសុខភាពពិភពលោក។ រាល់ការតាមដានបច្ចុប្បន្នភាពព័ត៌មានទាក់ទងនឹងជំងឺ. រាតត្បាតនេះ អាចចូលតាមដំណរខាងក្រោម៖

http://cdcmoh.gov.kh/ និង https://www.who.int/emergencies/diseases/novel-coronavirus-2019

៥) ត្រូវរាយការណ៍ដល់ប្រធានផ្នែកបុគ្គលិក និងអ្នកគ្រប់គ្រងផ្ទាល់របស់ខ្លួន ប្រសិនបើមានករណីសង្ស័យណាមួយទាក់ទងទៅនឹង **វីរុសកូវីត១៩**

៦) សូមថែរក្សាសមាជិកគ្រួសាររបស់ខ្លួន និងជូនដំណឹងថ្មីៗពីស្ថានភាព **វីរុសកូវីត១៩**



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

Accountability គណនេយ្យភាព
អភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ
05/10/2018 GPP 04/10/2021
Symbol of Trust និមិត្តសញ្ញានៃទំនុកចិត្ត

**កំរិតស្ថាប័នៈ**

១) មានរក្សាទុកដបទឹកអាល់កុល ឬទឹកអនាម័យសម្រាប់លាងដៃ នៅក្នុងបន្ទប់បុគ្គលិកនិមួយៗ ជាពិសេស នៅកន្លែងទទួលភ្ញៀវ និងស្នាក់ការសន្តិសុខ

២) បិតបង្ហាញ រូបសញ្ញាស្តីពីវិធានការបង្ការនិងទប់ស្កាត់ការរាតត្បាតនៃ **វីរុសកូវីត១៩** នៅក្នុងការិយាល័យរបស់ខ្លួន

៣) មិនលើកទឹកចិត្តដល់បុគ្គលិកទាំងអស់ ទៅបំពេញបេសកម្មនៅតាមបណ្តាខេត្តនានា និងនៅបរទេសរហូតដល់ចុងខែមេសា ២០២០

៤) ប្រើឧបករណ៍ត្រួតពិនិត្យកំដៅ ដើម្បីស្ទង់កំដៅដល់បុគ្គលិក និងភ្ញៀវ មុនពេលពួកគេដើរចូលក្នុងការិយាល័យ

៥) បង្កើតប្រព័ន្ធធ្វើការងារតាមរយៈអនឡាញ ដើម្បីមានភាពងាយស្រួលក្នុងការទំនាក់ទំនងការងារដល់អ្នកពាក់ព័ន្ធ

៦) អនុញ្ញាតអោយមានការរៀបចំជាកាលវិភាគ សម្រាប់ធ្វើការងារ ដោយរៀបចំអោយមានធ្វើការពីចំងាយ និងធ្វើការក្នុងការិយាល័យ (ដោយធ្វើការប្តូវេនគ្នាក្នុងចំណោមបុគ្គលិក)

៧) ផ្ញើរសេចក្តីជូនដំណឹងពីការពន្យាពេលធ្វើសកម្មភាពរបស់ខ្លួន ដល់ភាគីពាក់ព័ន្ធទាំងអស់ រួមមានសមាជិកដៃគូ និងម្ចាស់មូលនិធិ

៨) ធ្វើការជាមួយសមាជិកទាំងអស់ អំពីការពន្យាការបង់ថ្លៃសមាជិកភាពរហូតដល់ចុងខែ ឧសភាឆ្នាំ ២០២០

៩) ផ្តល់ព័ត៌មានថ្មីៗពីស្ថានភាព**វីរុសកូវីត១៩**ជូនដល់សមាជិក និងគិតគូរួមគ្នាប្រយុទ្ធប្រឆាំងនឹង**វីរុសកូវីត១៩**

១០) ទំនាក់ទំនងជាប្រចាំជាមួយរាជរដ្ឋាភិបាល ជាពិសេស ក្រសួងសុខាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលធ្វើការលើវិស័យសុខភាព ដើម្បីរួមកម្លាំងគ្នាទប់ទល់ការឆ្លងរាតត្បាត

១១) តាមដានយ៉ាងយកចិត្តទុកដាក់អំពី បច្ចុប្បន្នភាពនៃជំងឺរាតត្បាត **វីរុសកូវីត១៩** និងត្រួតពិនិត្យលើផលប៉ះពាល់លើការងារ របស់អង្គការ គ.ស.ក និងសមាជិក ហើយជូនដំណឹងពីផលប៉ះពាល់ដល់ដៃគូនានា បើមានករណីចាំបាច់



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

Accountability គណនេយ្យភាព
អភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ
GPP
05/10/2018 04/10/2021
Symbol of Trust និមិត្តសញ្ញានៃភាពទុកចិត្ត

បើមានចង្ងល់សូមទំនាក់ទំនងមកកាន់

1. លោក សឿង សារឿន នាយកប្រតិបត្តិ តាមរយៈសារអេឡិចត្រូនិច : ccc.director@ccc-cambodia.org, ឬតាមប្រព័ន្ធទូរស័ព្ទ / Telegram / Whatsapp លេខ: 085 777 954

2. លោកស្រី ស៊ិន ពុទ្ធារី ប្រធានផ្នែកទំនាក់ទំនង និងអភិវឌ្ឍន៍សមាជិក តាមរយៈសារអេឡិចត្រូនិច : putheary.sin@ccc-cambodia.org, ឬតាមប្រព័ន្ធទូរស័ព្ទ / Telegram / Whatsapp លេខ : 012 769836

3. លោកស្រី ចាន់ សូម៉ាលី តាមរយៈសារអេឡិចត្រូនិច : somaly.chan@ccc-camboida.org ឬតាមប្រព័ន្ធទូរស័ព្ទ / Telegram / Whatsapp លេខ: 092 959 709

សូមលើកទឹកចិត្តអោយបុគ្គលិកទាំងអស់ អាននូវរាល់ការណែនាំពីក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោក អំពីបច្ចុប្បន្នភាពនិង យល់ដឹងអំពីរោគសញ្ញានៃជំងឺរាតត្បាត **វីរុសកូវីត១៩**

ដោយក្តីគោរពរាប់អាន

**លោក សឿង សារឿន**

នាយកប្រតិបត្តិ
អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក)



www.ccc-cambodia.org
info@ccc-cambodia.org
T +855 (0)23 214 152
F +855 (0)23 216 009

#9-11, Street 476,
Toul Tompoung 1, Chamkamorn
P.O. Box 885, Phnom Penh,
Cambodia

Accountability គណនេយ្យភាព
GPP
05/10/2018 04/10/2021
Symbol of Trust